# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ : ១៩៩/២៤ ក.ប/ខ.ល

## សារលិខិតអបអរសាទរ

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា**

***ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!***

នាឱកាសដ៏មហានក្ខត្តឫក្សប្រកបដោយទឹកចិត្តសោមនស្សរីករាយ តាងនាមថ្នាក់ដឹកនាំ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្នុងនាមខ្ញុំបាទ និងភរិយា សូមសម្តែងនូវមនោសញ្ចេតនាយ៉ាងជ្រាលជ្រៅចូលរួមអបអរសាទរដោយស្មោះអស់ពីដួងចិត្តជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលត្រូវបានជ្រើសរើសជា **ប្រធានព្រឹទ្ធសភា** នៃព្រះរាជាណាចក្រកម្ពុជា ក្នុងការបោះឆ្នោតនៃសម័យប្រជុំដំបូង នីតិកាលទី៥ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នាថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៤។

ការទទួលបាននូវការជ្រើសតាំងនេះ គឺពិតជាមហាកិត្តិយសដ៏ធំធេងឧត្តុង្គឧត្តមសម្រាប់ប្រទេសជាតិ និងប្រជាជនខ្មែរគ្រប់រូប និងស័ក្តិសមបំផុតសម្រាប់ **សម្តេចអគ្គមហាសេនាបតីតេជោ** ដែលជាបិតាស្ថាបនិកសន្តិភាពរបស់ជាតិ ដែលកន្លងមកបានប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី មិនខ្លាចនឿយហត់យកជីវិតធ្វើជាដើមទុន និងហ៊ានធ្វើពលិកម្មគ្រប់បែបយ៉ាង ដើម្បីដណ្តើមបានមកវិញនូវសុខសន្តិភាព ស្ថិរភាព អធិបតេយ្យភាព និងប្រជាធិបតេយ្យ ជូនប្រទេសជាតិ និងប្រជាជន ព្រមទាំងបានដឹកនាំប្រទេសជាតិឱ្យមានការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យគួរជាទីមោទនៈ។

យើងខ្ញុំទាំងអស់គ្នា មានជំនឿយ៉ាងមុតមាំថា ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ** ក្នុងនីតិកាលថ្មីនេះ នឹងបន្តសម្រេចបានជោគជ័យបន្ថែមទៀត លើការពង្រឹងស្ថាប័ននីតិប្បញ្ញត្តិ លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋនៅកម្ពុជា ឱ្យបោះជំហានទៅមុខកាន់តែរឹងមាំ ក្រោមម្លប់ព្រះបារមីនៃអង្គ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ជាព្រះប្រមុខរដ្ឋ។

ឆ្លៀតក្នុងឱកាសដ៏មហាប្រសើរថ្លៃថ្លាឧត្តុង្គឧត្តមនេះ យើងខ្ញុំទាំងអស់គ្នា សូមលើកហត្ថប្រណម្យបួងសួងដល់គុណបុណ្យព្រះរតនត្រ័យកែវទាំងបី និងវត្ថុស័ក្តិសិទ្ធិក្នុងលោក សូមជួយថែរក្សា អភិបាលប្រោះព្រំសព្វសាធុការពរជ័យគ្រប់ប្រការជូន **សម្តេចអគ្គមហាសេនាបតីតេជោ** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី សូមបានប្រកបដោយពុទ្ធពរដ៏ប្រសើរថ្លៃថ្លាទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** មេត្តាទទួលនូវគារវភក្តីភាពដ៏ស្មោះស្ម័គ្រ និងអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់បំផុតពីយើងខ្ញុំ។

ថ្ងៃពុធ ១០រោច ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៤

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**រដ្ឋមន្ត្រី**

**ហេង សួរ**

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩